ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភាសាខ្មែរ

## អាន-សរសេរ



១

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

# អាន-សរសេរ

## ថ្នាក់ទី ១

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ២២៥៥ អយក.ប្រក. ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ**

បោះពុម្ពផ្សាយ ឆ្នាំ ២០១៤

ISBN 9-789-995-001-674

## គណៈកម្មការគ្រប់គ្រងកម្មវិធី

ឯកឧត្តម អ៊ឹម សិទ្ធី
ឯកឧត្តម ណាត ប៊ុនរឿន
ឯកឧត្តម កើ ណៃលាង
លោកជំទាវ ទន់ សាអ៊ីម
ឯកឧត្តម អ៊ូ អេង
លោក ចាន់ សុភា

## គណៈកម្មការនិពន្ធ

លោក ផាត់ វ៉ាន់ថន
លោក យិន ស៊ីដា
លោកស្រី ឈឹន ស៊ីវឡេង
លោក មួង ចាន់ទូច
លោកស្រី លី សាខុន
លោក សុខ បូរេត
លោកស្រី ម៉ៅ តាន់ណារី
លោក យិត សុភ័ក្រ្ត
លោក យ៉ោក សុវណ្ណ
លោក អ៊ុយ សាន
លោក ជិន សុកហេង
លោក កែវ សាវ៉ាត់

## គណៈកម្មការរៀបរៀង វិចិត្រករ និងរចនាទំព័រ

លោក យិន ស៊ីដា
លោក ញេប ប៊ុនស្រេង
លោក រ័ត្ន ប៊ុណ្ណា
លោក សួ ស៊ីផុន
លោក ហុង ពិដោរ
លោក ឡុង សុវណ្ណា(វិចិត្រករ)

## គណៈកម្មការពិនិត្យ

លោក ចាន់ សុភា

លោក អេង គឹមលី
លោក លាង សេងហាក់
លោក បេង ស៊ីម៉េត
លោក ជុំ សុផល

# អារម្ភកថា

សៀវភៅភាសាខ្មែរ "អាន-សរសេរ" ថ្នាក់ទី ១ នេះត្រូវបានរៀបចំឡើងដោយគណៈកម្មការនិពន្ធក្រសួងអប់រំ យុវជន និងកីឡា ដែលមានការចូលរួមសហការពីនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងលោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី ១ មួយចំនួនដែលស្ថិតនៅក្រោមគម្រោងកម្មវិធីសកម្មភាពពង្រីកការគាំទ្រវិស័យអប់រំ និងដៃគូអភិវឌ្ឍមួយចំនួន ។

សៀវភៅនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួល ដល់ការរៀនអក្សរដំបូងរបស់កុមារ ។ ខ្លឹមសារសំខាន់ៗនៃសៀវភៅនេះ មានការរៀបចំតាមលំដាប់ពីតិចទៅច្រើន ពីងាយទៅលំបាក ដើម្បីជួយដល់ការរៀនអក្សរដំបូងរបស់កុមារ ឱ្យចេះអាន(ចេះប្រកប)និងចេះសរសេរបានត្រឹមត្រូវ ដោយចាប់ផ្តើមដំបូងពី ការរៀនស្រៈ ព្យញ្ជនៈ ព្យញ្ជនៈផ្សំស្រៈប្រកប ស្រៈពេញតួ ផ្ញើជើង និងព្យាង្គតម្រួត ដោយចេះប្រកប ចេះអានពាក្យ ឃ្លា ល្បះ អត្ថបទខ្លីៗ និងចេះសរសេរបានត្រឹមត្រូវច្បាស់លាស់ តាមរយៈការហាត់អាន សរសេរ និងការធ្វើកិច្ចការផ្ទះ ។ ពិសេសគឺ ផ្តោតទៅលើការពង្រឹងសមត្ថភាពអាន និងសរសេរ ដែលជាមូលដ្ឋានគ្រឹះសំខាន់ ក្នុងការសិក្សាអក្សរដំបូងរបស់សិស្សថ្នាក់ទី ១ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅនេះនឹងបានជាប្រយោជន៍យ៉ាងច្រើនចំពោះសហគមន៍មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ក៏ដូចជាសាលារៀន គ្រូបង្រៀនក្នុងការជួយបង្រៀនកុមារឱ្យចេះអាន ចេះសរសេរគ្រប់គ្នា ហើយសិស្សមានសមត្ថភាពអាន និងសរសេររឹងមាំ អាចបន្តការសិក្សាទៅថ្នាក់បន្ទាប់ទៀតបានប្រកបដោយគុណភាពពិតប្រាកដ ។

**គណៈកម្មការនិពន្ធ**

# មាតិកា

## គណៈកម្មការគ្រប់គ្រងកម្មវិធី


អារម្ភកថា................................................ i

មាតិកា................................................ ii

១. សេចក្ដីណែនាំ................................................ iii

២. លំនាំបង្រៀន................................................ ix

៣. មេរៀន

- រៀនគូសបន្ទាត់ និងខ្សែកោង................................................ ១
- ចម្រៀងស្រះ................................................ ២
- ស្រះនិស្ស័យ................................................ ៣
- ចម្រៀងអក្ខរក្រម................................................ ៤
- ព្យញ្ជនៈ ៣៣ តួ................................................ ៥
- ព្យញ្ជនៈពួក អ................................................ ៦
- ព្យញ្ជនៈពួក អ៊................................................ ២១
- រៀនសាឡើងវិញព្យញ្ជនៈពួក អ និងពួកអ៊................................................ ៣៨
- បទចម្រៀង សារិកាកែវអើយ................................................ ៣៩
- សញ្ញាមូសិកទន្ត ឬសញ្ញាធ្មេញកណ្ដុរ ( ៉ )................................................ ៤០
- សញ្ញាត្រីស័ព្ទ ឬសញ្ញាសក់ ក ( ៊ )................................................ ៤៨
- ប្រកប................................................ ៥៤
- ស្រះពេញតួ................................................ ៨១
- ព្យញ្ជនៈ និងជើងព្យញ្ជនៈ................................................ ៨៤
- ព្យញ្ជនៈផ្ញើជើង................................................ ៨៥
- ព្យាង្គតម្រួត................................................ ១២២
- អត្ថបទ " អ្នកគ្រូខ្ញុំ "................................................ ១៣៣
- អត្ថបទ " សាលារៀនខ្ញុំ "................................................ ១៣៤

៤. បទានុក្រម................................................ ១៣៥

# សេចក្តីណែនាំ

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថា សិស្សបឋមសិក្សាមានមូលដ្ឋាននៃការអាន និងសរសេរ នៅមានកម្រិតទាបគួរឱ្យបារម្ភ ។ ក្រសួងអប់រំ យុវជន និងកីឡា បានរិះរកយុទ្ធវិធី ដើម្បីពង្រឹងគុណភាពនៃការអាន និងសរសេរ ឱ្យបានកាន់តែប្រសើរ ដោយធ្វើការសម្រួលវិធីសាស្ត្រ និងកែលម្អឯកសារសម្រាប់បង្រៀនភាសាខ្មែរថ្នាក់ទី ១ ឡើងវិញ ដើម្បីឱ្យសិស្សថ្នាក់ទី១ អាចរៀនភាសាខ្មែរឆាប់ចេះ ក្នុងទិសដៅឆ្លើយតបទៅនឹងគោលនយោបាយ សម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាដែលបានចែងថា សិស្សថ្នាក់ទី ១ ដល់ទី ៣ ត្រូវមានបំណិនមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរ និងគណិតវិទ្យាពោលគឺចេះអាន សរសេរ និងគិតលេខបានច្បាស់លាស់ ។

សៀវភៅសម្រាប់បង្រៀនអក្សរថ្នាក់ទី ១ ថ្មីនេះ រៀបរៀងឡើងដើម្បីសម្រួលដល់ការរៀន និងការបង្រៀនភាសាខ្មែរ ដោយដកស្រង់ខ្លឹមសារមួយចំនួន និងយកតាមលំនាំសៀវភៅថ្នាក់ទី ១ ពីសម័យមុនៗ មកធ្វើបច្ចុប្បន្នភាពឱ្យស្របតាមបរិបទថ្មី ។ សៀវភៅនេះចាប់ផ្តើមពី ការរៀនគូសបន្ទាត់ ស្រៈនិស្ស័យ ព្យញ្ជនៈ ព្យញ្ជនៈផ្សំនឹងស្រៈ ប្រកប ព្យញ្ជនៈផ្ញើជើង ព្យាង្គតម្រួត ដើម្បីឱ្យសិស្សមានបំណិនរឹងមាំក្នុងការអាន ផ្សំព្យញ្ជនៈជាមួយស្រៈ និងឈានឆ្ពោះទៅប្រកប អានពាក្យ អានល្បះ និងអានអត្ថបទ ។ ក្រសួងអប់រំ យុវជន និងកីឡាប្រើប្រាស់សៀវភៅនេះ ដើម្បីអនុវត្តទូទាំងប្រទេស បន្ទាប់ពីបានធ្វើការសាកល្បងពេញមួយឆ្នាំសិក្សា ប្រកបដោយជោគជ័យ នៅតាមសាលាគោលដៅនៃរាជធានី ខេត្តមួយចំនួន ។

ដើម្បីជាជំនួយដល់គ្រូក្នុងការប្រើប្រាស់សៀវភៅនេះបានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្តីណែនាំអមក្នុងសៀវភៅនេះ ដោយផ្តោតលើ ៖

១. ការប្រើប្រាស់ម៉ោងសិក្សា

២. វិធីសាស្ត្រ

៣. ការប្រើប្រាស់សម្ភារៈ

៤. ការវាយតម្លៃ

៥. ការដាក់កិច្ចការផ្ទះ

៦. លំនាំបង្រៀន ។

## ១ . ការប្រើប្រាស់ម៉ោងសិក្សា

កម្មវិធីសិក្សាថ្មី តម្រូវឱ្យសិស្សសិក្សាភាសាខ្មែរចំនួន ១៣ម៉ោងក្នុងមួយសប្តាហ៍ ហើយក្នុង១ម៉ោងសិក្សាមានរយៈពេល ៤០នាទី ។ ក្នុងមួយឆ្នាំសិក្សាសិស្សត្រូវរៀន ៣៨សប្តាហ៍ ។ ដូច្នេះ ម៉ោងសម្រាប់រៀនភាសាខ្មែរស្មើនឹង ៤៩៤ម៉ោងសិក្សា ។

ខាងក្រោមនេះ ជាកាលវិភាគសម្រាប់មុខវិជ្ជាភាសាខ្មែរក្នុង ១សប្តាហ៍ ៖

| ថ្ងៃ | ចំនួនម៉ោងសិក្សា |
|---|---|
| ចន្ទ | ០៣ម៉ោង |
| អង្គារ | ០២ម៉ោង |
| ពុធ | ០៣ម៉ោង |
| សុក្រ | ០២ម៉ោង |
| សៅរ៍ | ០៣ម៉ោង |
| សរុប | ១៣ម៉ោង |

ចំនួនម៉ោងបង្រៀន នៅតាមទំព័រមេរៀននីមួយៗខុសៗគ្នា ។ ខ្លឹមសារមេរៀនខ្លះ ក្នុងមួយទំព័រត្រូវបង្រៀន២ម៉ោង ខ្លះ ៣ម៉ោង ខ្លះ ៤ម៉ោង ខ្លះ ៥ម៉ោង ខ្លះទៀតលើសពីដប់ម៉ោងក៏មាន ។ អាស្រ័យហេតុនេះ មុនពេលរៀបចំការបង្រៀនអ្នកគ្រូ លោកគ្រូ គប្បីមើលតារាងបែងចែកម៉ោងសិក្សាខាងក្រោមជាមុនសិន ។

# តារាងបែងចែកម៉ោងសិក្សាសម្រាប់មេរៀន

| ល.រ | ខ្លឹមសារមេរៀន | ចំនួនម៉ោងសិក្សា | ផ្សេងៗ |
|---|---|---|---|
| ១ | ការរៀនគូសបន្ទាត់ | ០៦ ម៉ោង | ត្រីមាសទី ១<br>- ម៉ោងសរុប ១៣ម៉ x ១៣សប្តាហ៍ = ១៦៩ម៉<br>- ម៉ោងបង្រៀន ១៦២ម៉<br>- ម៉ោងនៅសល់ ០៧ម៉ |
| ២ | ចម្រៀងស្រៈ | ០២ ម៉ោង | |
| ៣ | ស្រៈនិស្ស័យ ២៣តួ | ១៦ ម៉ោង | |
| ៤ | ព្យញ្ជនៈ ៣៣តួ អមដោយចម្រៀង | ០៨ ម៉ោង | |
| ៥ | ព្យញ្ជនៈពួក "អ" ផ្សំនឹងស្រៈ | ៥៨ ម៉ោង | |
| ៦ | ព្យញ្ជនៈពួក "អ៊" ផ្សំនឹងស្រៈ | ៧២ ម៉ោង | |
| ៧ | បទចម្រៀងសារិកាកែវអើយ | ០២ ម៉ោង | ត្រីមាសទី ២<br>- ម៉ោងសរុប ១៣ម៉ x ១៣សប្តាហ៍ = ១៦៩ម៉<br>- ម៉ោងបង្រៀន ១៦៧ម៉<br>- ម៉ោងនៅសល់ ០០ម៉<br>(ចំពោះម៉ោងនៅសល់អាចដកម៉ោងពីត្រីមាសទី ៣ មកប្រើបាន) |
| ៨ | ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ | ២៤ ម៉ោង | |
| ៩ | ប៊ ស៊ ហ៊ អ៊ | ១៥ ម៉ោង | |
| ១០ | មេសូត្ររត់មាត់ ម៉ែឪមានគុណ | ០២ ម៉ោង | |
| ១១ | ប្រកប | ៨១ ម៉ោង | |
| ១២ | ស្រៈពេញតួ | ១០ ម៉ោង | |
| ១៣ | ព្យញ្ជនៈ និងជើង | ០៨ ម៉ោង | |
| ១៤ | ព្យញ្ជនៈផ្ញើជើង ក្ក ដល់ ឃ្ន ឃ្ល ឃ្វ | ២៧ ម៉ោង | |
| ១៥ | ចម្រៀង "ពេលដើរទៅសាលារៀន" | ០២ ម៉ោង | ត្រីមាសទី ៣<br>- ម៉ោងសរុប ១៣ម៉ x ១២សប្តាហ៍ = ១៥៦ម៉<br>- ម៉ោងបង្រៀន ១៣២ម៉<br>- ម៉ោងនៅសល់ ២៤ម៉ |
| ១៦ | ព្យញ្ជនៈផ្ញើជើង(ត) ច្ប ច្ន ច្យ ដល់ចប់ | ៨១ ម៉ោង | |
| ១៧ | ព្យាង្គតម្រួត | ៤១ ម៉ោង | |
| ១៨ | អត្ថបទអំណាន | ០៨ ម៉ោង | |

- សរុបម៉ោងក្នុងកម្មវិធីសិក្សា : ១៣ម៉ x ៣៨សប្តាហ៍ = ៤៩៤ ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន : = ៤៦៣ ម៉ោងសិក្សា
- សរុបម៉ោងសល់ / បម្រុង : = ៣១ ម៉ោងសិក្សា

*កំណត់សម្គាល់* ៖ ម៉ោងសិក្សាសរុបក្នុងកម្មវិធីសិក្សាមាន ៤៩៤ម៉ោង(ម៉ោងបង្រៀនសរុប ៤៦៣ម៉ោង នៅសល់ ៣១ម៉ោង ដែលគ្រូអាចបង្រៀនសាឡើងវិញ ឬធ្វើលំហាត់បន្ថែម) ។

## ២ . វិធីសាស្ត្រ

មុននឹងបង្រៀនតួអក្សរ គ្រូត្រូវបញ្ជាក់ទីតាំង និងបង្រៀនគូសផ្នែកនៃតួអក្សរ(បន្ទាត់ និងខ្សែកោង) ជាមុនសិនដូចជា បន្ទាត់ផ្ដេក បញ្ឈរ កាច់ កោង មូល... ដើម្បីសម្របសម្រួលចលនាដៃទៅតាមភ្នែកដែលកុមារមើលឃើញ ។ កុមារតូចៗភាគច្រើន នៅមានការច្រឡំក្នុងការគូសពីឆ្វេងទៅស្ដាំ លើ ក្រោម មុខ ក្រោយ នៅឡើយ ។ ចំណែកដៃរបស់គេ នៅមានការលំបាកក្នុងការចាប់កាន់ខ្មៅដៃ ឬដីសដើម្បីគូស ឬសរសេរ ។ ដូច្នេះ នៅពេលបង្រៀនគូសបន្ទាត់ ឬសរសេរស្រៈ ព្យញ្ជនៈ គ្រូគប្បីយកចិត្តទុកដាក់ណែនាំសិស្សឱ្យបានច្បាស់លាស់អំពីការគូស និងសរសេរដែលត្រូវចាប់ផ្ដើម និងបញ្ចប់ ហើយតាមដានការគូស ឬសរសេររបស់សិស្សឱ្យបានហ្មត់ចត់តាមទម្រង់ ទំហំឱ្យបានច្បាស់លាស់ត្រឹមត្រូវ ដើម្បីកុំឱ្យគេគូស ឬសរសេរបញ្ច្រាស ។

បន្ទាប់ពីសិស្សមានមូលដ្ឋានគ្រឹះក្នុងការគូសបន្ទាត់ និងផ្នែកនៃតួអក្សររួចមក អ្នកគ្រូ លោកគ្រូអាចបង្រៀនតួអក្សរ (ស្រៈ ព្យញ្ជនៈ) ដោយធ្វើឱ្យពួកគេស្គាល់អក្សរនីមួយៗច្បាស់លាស់ ហើយចេះអាន និងសរសេរបានត្រឹមត្រូវ ។ បន្ទាប់មកទៀត គ្រូប្រើប្រាស់ចំណេះដឹងបន្តទៅបង្រៀនព្យាង្គ ពោលគឺផ្សំព្យញ្ជនៈនីមួយៗនឹងស្រៈទាំង ២៣តួ ។ ក្នុងការបង្រៀនព្យាង្គ(ការផ្សំព្យញ្ជនៈនឹងស្រៈ) គ្រូគប្បីប្រុងប្រយ័ត្នគ្រប់គ្រងសិស្ស និងតាមដានឱ្យបានច្បាស់លាស់ ដើម្បីកុំឱ្យសិស្សរៀនតាមបែបចាំមាត់ តែពុំស្គាល់តួអក្សរច្បាស់លាស់ ។ ដូច្នេះ ការរៀនអានបែបប្រកប និងការរៀនសរសេរជាការចាំបាច់បំផុត ។ បន្ទាប់មកទើបបង្រៀនពាក្យ ល្បះ និងអត្ថបទ ។ ដើម្បីទទួលបានជោគជ័យ គ្រូគប្បីយកចិត្តទុកដាក់លើការជួយសិស្សឱ្យចេះអាននិងសរសេរបានត្រឹមត្រូវ ដោយគួបផ្សំជាមួយការប្រើប្រាស់សម្ភារៈក្នុងការបង្រៀនពាក្យនិងល្បះផងដែរ ។ វិធីនេះ ជួយឱ្យសិស្សមានមូលដ្ឋានរឹងមាំក្នុងការប្រកបពាក្យ ។

ក្នុងការបង្រៀន គ្រូត្រូវចេះលើកទឹកចិត្តសិស្សដោយសរសើរគេ ហើយមិនត្រូវនិយាយបង្អាប់សិស្ស មិនធ្វើឥរិយាបថដែលនាំឱ្យគេខ្លាចមិនហ៊ានចូលរួម មិនហ៊ាននិយាយ តែត្រូវជួយពួកគេឱ្យមានសង្ឃឹម ហ៊ានសាកសួរ និងបង្កឱ្យមានបរិយាកាសសប្បាយរីករាយជាប្រចាំ ស្របតាមកម្មវិធីសាលាកុមារមេត្រី ។

## ៣ . ការប្រើប្រាស់សម្ភារៈ

ក្នុងការបង្រៀន អ្នកគ្រូ លោកគ្រូគប្បីប្រើប្រាស់សម្ភារឧបទេស ពីព្រោះវាជាមធ្យោបាយមួយទាក់ទាញទឹកចិត្តសិស្សឱ្យចូលចិត្តរៀន មានការចងចាំ តាមរយៈការលើកបង្ហាញ និងចង្អុល ធ្វើឱ្យសិស្សបានសប្បាយ ហើយថែមទាំងយល់មេរៀនបានច្បាស់លាស់(យល់ន័យពាក្យ ល្បះ និងអត្ថបទ)ទៀតផង ។

សម្ភារៈដែលចាំបាច់បំផុតសម្រាប់បង្រៀនអាន និងសរសេរ គឺអក្សរចល័ត ប័ណ្ណពាក្យ តារាងស្រៈ ២៣តួ តារាងព្យញ្ជនៈ ៣៣តួ និងជើងព្យញ្ជនៈ តារាងស្រៈពេញតួ និងដីសពណ៌ ។ ក្រៅពីនេះ នៅមានរូបភាព និងវត្ថុជាក់ស្តែងផ្សេងទៀត តម្រូវទៅតាមពាក្យដែលត្រូវបង្រៀន ។

គ្រូអាចធ្វើបណ្ណពាក្យ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន ហើយអាចទុកប្រើប្រាស់បានយូរមិនអស់ប្រាក់កាសច្រើន ដោយកាត់ក្តារឆ្នួន ឬក្រដាសកាតុង ឬក្រដាសឡាំង ដែលមានទំហំសមស្របសម្រាប់សរសេរពាក្យ១ព្យាង្គ ២ព្យាង្គ ឬ៣ព្យាង្គ។ ប្រសិនបើក្រដាសឡាំង ត្រូវយកប្លាស្ទិចបិទពីលើឱ្យជិតសម្រាប់សរសេរជាមួយហ្វឺតអាចលុបវិញបាន ហើយទុកប្រើថ្ងៃក្រោយទៀត ។ ចំណែកសិស្ស ត្រូវមានក្តារឆ្នួន ដីសជាចាំបាច់ និងអក្សរចល័តតូចៗ(ប្រសិនបើអាចរកបាន) ។

## ៤ . ការវាយតម្លៃ

នៅពេលបង្រៀនមេរៀនចប់ គ្រូត្រូវធ្វើការវាយតម្លៃ ដើម្បីវាស់ស្ទង់លទ្ធផលនៃការសិក្សារបស់សិស្ស ។ ការវាយតម្លៃត្រូវធ្វើជាប្រចាំ តាមដំណាក់ និងការប្រឡងប្រចាំខែ ប្រចាំឆមាស ។ ការវាយតម្លៃត្រូវសមស្របនឹងលទ្ធផលសិក្សាថ្នាក់ទី១ ដូចជាក្នុងការវាយតម្លៃការអាន ត្រូវឱ្យសិស្សអានស្រៈ ព្យញ្ជនៈ ស្រៈពេញតួ ពាក្យ ល្បះ អត្ថបទ ឬរៀបតួអក្សរតាមលំដាប់ ។ល ។ ចំណែកការវាយតម្លៃការសរសេរ ត្រូវឱ្យសិស្សចម្លង និងសរសេរអក្សរទាំងអស់នៃអក្ខរក្រម(ក ខ ... អ) សរសេរតាមអាន ពាក្យ និងកន្សោមពាក្យងាយៗ សរសេរចំណងជើងរូបភាព ។ល ។

## ៥ . ការដាក់កិច្ចការផ្ទះ

ការដាក់កិច្ចការផ្ទះ ជាមធ្យោបាយមួយសំខាន់ សម្រាប់ជួយសិស្សឱ្យឆាប់ចេះអាននិងសរសេរ និងជាទម្លាប់មួយឱ្យសិស្សចេះរៀនដោយខ្លួនឯង និងចូលចិត្តរៀន ។ គ្រូគប្បីដាក់កិច្ចការផ្ទះរាល់ថ្ងៃ ។

កិច្ចការផ្ទះសម្រាប់សិស្សថ្នាក់ទី១ អាចធ្វើបានតាមរូបភាពពីរយ៉ាង ៖

- ទីមួយ ឱ្យសិស្សអាន និងសរសេរអ្វីដែលគេបានរៀនរួចហើយឡើងវិញ ឱ្យសិស្សធ្វើលំហាត់ផ្សេងៗ ទាក់ទងនឹងមេរៀន ដែលបានរៀនរួចដើម្បីពង្រឹងចំណេះដឹង ។ នៅពេលរៀនតួអក្សរ ត្រូវឱ្យសរសេរជាអក្សរផ្ចង់ឱ្យស្អាត ហើយគ្រូកែនៅថ្ងៃបន្ទាប់ ។
- ទីពីរ ឱ្យសិស្សរៀនមេរៀនថ្មីត្រៀមទុកជាមុនដូចជាអាន និងសរសេរតួអក្សរ ឬពាក្យដែលនឹងត្រូវរៀននៅថ្ងៃបន្ទាប់ ។ ចំពោះពាក្យ ឬឃ្លាក្នុងសៀវភៅអាន-សរសេរថ្នាក់ទី១ ដែលគ្រូមិនបានបង្រៀននៅក្នុងថ្នាក់ ត្រូវដាក់កិច្ចការផ្ទះឱ្យសិស្សអានបន្ថែម ឬសរសេរនៅផ្ទះ ។

គ្រប់មេរៀន ត្រូវមានកិច្ចការផ្ទះ ។ គ្រូត្រូវដាក់កិច្ចការផ្ទះ ឱ្យសិស្សធ្វើចាប់ពីមេរៀនទី១ឱ្យស្រប តាមការវិវត្តរបស់សិស្ស ដែលក្នុងនោះអាចឱ្យសិស្ស ៖

- រៀនគូសបន្ទាត់ឈរ ទ្រេត ផ្តេក ខ្សែកោង ...
- ចម្លងស្រៈនិងព្យញ្ជនៈ ដែលបានរៀនរួចហើយ (ដាក់ក្នុងសៀវភៅកិច្ចការផ្ទះ)
- ចម្លងពាក្យនិងល្បះដែលបានរៀន
- បំពេញស្រៈ ឬព្យញ្ជនៈ ដើម្បីបង្កើតពាក្យ (ក េ ក រ = កកេរ)
- សរសេរពាក្យតម្រូវទៅនឹងរូបភាព
- ភ្ជាប់រូបទៅនឹងពាក្យ (រូប ... ពាក្យ)

*កំណត់សម្គាល់ ៖*

- គ្រប់កិច្ចការអ្នកគ្រូ លោកគ្រូ ត្រូវត្រួតពិនិត្យ និងកែឱ្យបានទៀងទាត់ជាប្រចាំ និងប្រាប់កំហុសសិស្សឱ្យបានច្បាស់លាស់ ។
- គ្រប់មេរៀនត្រូវមានកិច្ចការផ្ទះជាប្រចាំ មិនចំពោះតែមេរៀនសាឡើងវិញនោះទេ ។

## ៦ . លំនាំបង្រៀន

### ៦.១ លំនាំបង្រៀន គូសបន្ទាត់ (ផ្នែកនៃតួអក្សរ)

- គ្រូគូសបន្ទាត់មួយ ដូចបន្ទាត់គំរូក្នុងសៀវភៅសិស្ស នៅលើក្ដារខៀនបង្ហាញសិស្ស ដោយគូសសញ្ញាព្រួញនៅក្បែរបន្ទាត់នោះផង ដើម្បីបង្ហាញទិសចាប់ផ្ដើម និងទិសបញ្ចប់ ហើយប្រាប់សិស្សឱ្យយល់សញ្ញាព្រួញនោះផង ។
- គ្រូគូសជាលើកទី ២ ដោយនិយាយបណ្ដើរ គូសបណ្ដើរ ។ ***ឧទាហរណ៍*** ខ្ញុំគូសពីឆ្វេងទៅស្ដាំ ។
- គ្រូនាំសិស្សគូសបន្ទាត់នោះក្នុងលំហ(លើខ្យល់) ដោយគ្រូបែរខ្នងបញ្ឆិតបន្តិច ហើយលើកដៃទៅមុខ ឱ្យសិស្សក្រោកឈរ ហើយធ្វើតាមគ្រូទាំងអស់គ្នា ។ គ្រូយកចង្អុលដៃគូសក្នុងខ្យល់ពីឆ្វេងទៅស្ដាំ ឱ្យសិស្សធ្វើតាមជាច្រើនសា ព្រមទាំងនិយាយផង ។
- ឱ្យសិស្សបើកសៀវភៅអាន-សរសេរ ហើយយកចង្អុលដៃគូសតាមបន្ទាត់នោះ តាមសញ្ញាព្រួញ ។
- គ្រូឱ្យសិស្សគូសបន្ទាត់នៅលើក្ដារឆ្នួនឱ្យបានច្រើនសា រួចពិនិត្យមើល ។ ប្រសិនបើសិស្សគូសខុសគ្រូត្រូវប្រាប់សិស្សឱ្យកែឡើងវិញរហូតដល់ត្រូវ រួចចម្លងដាក់សៀវភៅរៀងៗខ្លួន ។

*ចំណាំ ៖* គ្រូបង្រៀនគូសបន្ទាត់ផ្សេងទៀត ដោយធ្វើតាមលំនាំខាងលើ ។

### ៦.២ លំនាំបង្រៀនអាន និងសរសេរស្រៈនិស្ស័យ

- គ្រូបង្ហាញវត្ថុជាក់ស្ដែង ឬរូបភាពដែលមានសូរស្រៈ ដែលត្រូវរៀននៅក្នុងនោះ ឬគ្រូអាចហៅឈ្មោះសិស្ស ដែលមានសូរស្រៈនោះក៏បាន ។ ***ឧទាហរណ៍*** បង្រៀនស្រៈ "ា" គ្រូលើក កាទឹកបង្ហាញសិស្ស ឱ្យសិស្សប្រាប់ឈ្មោះវត្ថុនោះ ។
- គ្រូអានពាក្យ "កា"ដោយសង្កត់សូរសំឡេងលើស្រៈ "ា" ។ គ្រូបន្លឺស្រៈ [អា] ឱ្យសិស្សថាតាម ។
- គ្រូលើកស្រៈចល័ត "ា" បង្ហាញសិស្ស និងឱ្យសិស្សបន្លឺស្រៈ [អា] ម្នាក់ម្ដងៗ រួចមួយក្រុមម្ដងទីបញ្ចប់ថាទាំងអស់គ្នា ។
- ឱ្យសិស្សចង្អុលបង្ហាញស្រៈ "ា" នៅក្នុងសៀវភៅរបស់គេ និងនៅក្នុងតារាងផ្សេងៗ ឬរកស្រៈ "ា" ក្នុងចំណោមស្រៈចល័ត ។
- គ្រូប្រាប់ពាក្យមួយចំនួនដែលមានសូរ "ា" ដូចជា តា ខា ហើយឱ្យសិស្សរកពាក្យផ្សេងទៀតដែលមានសូរ "ា" ។

*ចំណាំ ៖* គ្រូបង្រៀនស្រៈផ្សេងទៀត ដោយធ្វើតាមលំនាំបង្រៀនស្រៈ "ា" ដែរ ។

- គ្រូសរសេរស្រៈ "ា" នៅលើក្ដារខៀន ដោយមានសញ្ញាព្រួញអមផង ។ គ្រូចង្អុលស្រៈ "ា" ឱ្យសិស្សអានម្នាក់ម្ដងៗ រួចអានទាំងអស់គ្នា ។
- គ្រូសរសេរស្រៈ "ា" ឱ្យសិស្សមើលព្រមទាំងនិយាយ ខ្ញុំគូសពីឆ្វេងទៅស្ដាំ ពីលើចុះក្រោម ។
- គ្រូនាំសិស្សសរសេរស្រៈលើខ្យល់ និងឱ្យសិស្សនិយាយបណ្ដើរ ។ គ្រូពិនិត្យក្រែងមានសិស្សគូសសញ្ញាបញ្ច្រាសទិស ។
- ឱ្យសិស្សយកចង្អុលដៃសរសេរស្រៈ តាមលំដាប់សញ្ញាព្រួញ ក្នុងសៀវភៅសិស្ស ។
- ឱ្យសិស្សសរសេរស្រៈ "ា" លើក្ដារឆ្នួន ។ គ្រូដើរពិនិត្យ និងកែលម្អសិស្សដែលសរសេរខុស ។
- ហៅសិស្ស ៣-៤ នាក់ ឡើងសរសេរស្រៈនៅលើក្ដារខៀន និងបន្លឺសូរស្រៈនោះផង ។

*ចំណាំ ៖* គ្រូបង្រៀនសរសេរស្រៈផ្សេងទៀត ដោយធ្វើតាមលំនាំបង្រៀនខាងលើ ។

*បញ្ជាក់ ៖* ប្រសិនបើក្នុងមួយពេលត្រូវបង្រៀនស្រៈលើសពីពីរ គ្រូគប្បីចង្អុល ឬហៅស្រៈឆ្លាស់គ្នាឱ្យសិស្សអាន និងសរសេរ ។ គ្រូមិនត្រូវបង្រៀនអាន ១ថ្ងៃ ហើយសរសេរ ១ថ្ងៃដាច់ពីគ្នាទេ ។ ការអាននិងសរសេរ ត្រូវតែបង្រៀនបន្តគ្នានៅថ្ងៃជាមួយគ្នា ឬអាននិងសរសេរជាមួយគ្នា ។

## ៦.៣ លំនាំបង្រៀនអានព្យញ្ជនៈ

- គ្រូបិទផ្ទាំងចម្រៀង កខ ... ឬចម្រៀងតួអក្សរវគ្គទី១នៅលើក្ដារខៀន ។ គ្រូច្រៀងចម្រៀងមួយវគ្គឱ្យសិស្សស្ដាប់ ព្រមទាំងចង្អុលចំៗតួអក្សរ ក ខ គ ឃ ង ។
- គ្រូ និងសិស្សច្រៀងជាមួយគ្នា ដោយគ្រូចង្អុលចំៗតួអក្សរផង ។
- គ្រូបន្លឺសូរ [ក] រួចឱ្យសិស្សចង្អុលតួអក្សរ ក នៅលើផ្ទាំងចម្រៀង ។ បន្ទាប់មក ឱ្យសិស្សចង្អុលអក្សរ ក នៅលើតារាងព្យញ្ជនៈ ៣៣តួ ។
- គ្រូបង្ហាញអក្សរចល័ត ក និងបន្លឺសូរ [ក] ។ ឱ្យសិស្សបន្លឺសូរ [ក] ជាបុគ្គល រួចជាក្រុមតាមជួរតុ រួចទាំងអស់គ្នា ។
- គ្រូសរសេរព្យញ្ជនៈ ក នៅលើក្ដារខៀន ដោយអក្សរធំៗ ។

  *ចំណាំ ៖* ចំពោះព្យញ្ជនៈផ្សេងទៀត គប្បីបង្រៀនដូចព្យញ្ជនៈ ក ដែរ ។
- គ្រូអានព្យញ្ជនៈមួយម្ដងៗ ដោយចង្អុលចំៗតួអក្សរ ឱ្យសិស្សថាតាមជាក្រុមតូចៗ ។

- គ្រូហៅសិស្សឡើងអានម្នាក់ម្ដងៗ ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ ។
- គ្រូចង្អុលព្យញ្ជនៈឆ្លាស់គ្នាឱ្យសិស្សអាន រួចឱ្យអានបញ្ច្រាស ដើម្បីឱ្យសិស្សចំណាំតួអក្សរបានច្បាស់ ។ គ្រូអានហើយ ឱ្យសិស្សឡើងចង្អុល ។
- គ្រូហៅសិស្សឡើងបង្ហាញព្យញ្ជនៈចល័តមួយម្ដងៗ រហូតដល់ចប់ ។
- ឱ្យសិស្សអានព្យញ្ជនៈ នៅក្នុងសៀវភៅអាន-សរសេរថ្នាក់ទី១ របស់គេជាដៃគូ ដោយម្នាក់ចង្អុលឆ្លាស់ចុះឆ្លាស់ឡើង ហើយម្នាក់ទៀតអាន រួចប្ដូរវេនគ្នា ។

  *កំណត់សម្គាល់ ៖* ក្នុងពេលនេះ មិនទាន់តម្រូវឱ្យសិស្សរៀនសរសេរ ក ខ ទេ គឺគ្រាន់តែអានប៉ុណ្ណោះ ។

## ៦.៤ លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈពួក អ ផ្សំនឹងស្រៈ

### ក. ការបង្រៀនអានព្យាង្គ (ក កា កិ កី កឹ កឺ ...កោះ)

- គ្រូលើកអក្សរចល័ត ក រួចសួរសិស្ស តើនេះជាអក្សរអ្វី ? គ្រូបង្ហាញស្រៈ ា រួចសួរសិស្ស តើនេះជាស្រៈអ្វី? គ្រូយក ក ផ្សំនឹងស្រៈ ា គ្រូអានជាគំរូ ក ា កា រួចឱ្យសិស្សអានតាម ។ គ្រូសរសេរ កា នៅលើក្ដារខៀន ។
- គ្រូបង្រៀនព្យញ្ជនៈ ក នឹងស្រៈផ្សេងទៀតរហូតដល់ស្រៈ ោះ ដោយធ្វើតាមលំនាំបង្រៀន ក និងស្រៈ ា ដែរ ។
- គ្រូចង្អុល និងអានព្យាង្គមួយម្ដងៗ ឱ្យសិស្សស្ដាប់ដូចខាងក្រោម ៖

  ក ា កា , ក ិ កិ , ក ី កី ... ក ុំ កុំ , ក ំ កំ , ក ាំ កាំ

  ក ះ កះ , ក ុះ កុះ , ក េះ កេះ , ក ោះ កោះ ។
- គ្រូនិងសិស្សអានជាមួយគ្នាពីដើមដល់ចប់ ដោយគ្រូចង្អុលតាមលំដាប់ រួចបញ្ច្រាសមកវិញ រួចឆ្លាស់ចុះឡើង ។
- ឱ្យសិស្សអានឱ្យបានច្រើនដង រហូតដល់ចាំមាត់ជាបុគ្គល ជាក្រុមតូច និងទូទាំងថ្នាក់ ។
- បន្ទាប់មក គ្រូចង្អុល និងអាន ដោយមិនបាច់ប្រកប ឱ្យសិស្សថាតាមដូចខាងក្រោម ៖

  ក កា កិ កី ...............កុំ កំ កាំ កះ កុះ កេះ កោះ ។
- គ្រូនិងសិស្សអានជាមួយគ្នាពីដើមដល់ចប់ ដោយគ្រូជាអ្នកចង្អុល ។

- ឱ្យសិស្សអានជាក្រុមតាមជួរតុ រួចអានម្នាក់ម្តងៗ ។ ឱ្យសិស្សអានច្រាសមកវិញ ។ កោះ កេះ កុះ ...កា ។
- ឱ្យសិស្សអានសៀវភៅរបស់ពួកគេជាដៃគូ រួចជាបុគ្គល ។

  *ចំណាំ ៖* ចំពោះព្យញ្ជនៈផ្សំនឹងស្រៈផ្សេងទៀត គ្រូគប្បីបង្រៀនតាមលំនាំការបង្រៀនខាងលើនេះដែរ ។

  *កំណត់សម្គាល់ ៖*

  - គ្រូអាចចម្លងព្យញ្ជនៈផ្សំស្រៈ ក កា កិ កី ...កោះ ដាក់លើក្តារខៀនទុកមុនក៏បាន ប៉ុន្តែត្រូវបង្រៀនការផ្សំ ដោយប្រើអក្សរចល័តមួយម្តងៗ មុនឱ្យសិស្សអាន ។
  - នៅពេលសិស្សអានការផ្សំបានរត់មាត់ហើយ មេរៀនក្រោយៗគ្រូមិនគប្បីប្រើពេលយូរក្នុងការផ្សំព្យញ្ជនៈនឹងស្រៈ ដូចពេលមុនទេ ។

## ខ. ការបង្រៀនពាក្យ

- គ្រូបង្ហាញសម្ភារៈជាក់ស្តែង រូបភាព ធ្វើកាយវិការ លើកឧទាហរណ៍ ធ្វើការប្រៀបធៀប ឬសួរសំណួរតម្រូវទៅតាមប្រភេទពាក្យ(នាម គុណនាម កិរិយា) ដើម្បីបង្កើតពាក្យដែលត្រូវរៀន ។ ឱ្យសិស្សថាពាក្យនោះ ៣-៤នាក់ ។
- គ្រូបង្ហាញប័ណ្ណពាក្យ រួចសរសេរពាក្យលើក្តារខៀនឱ្យសិស្សអានជាបុគ្គល ។
- គ្រូនាំសិស្សបំបែកពាក្យ ដោយសួរសិស្សថា តើពាក្យ ...... មានព្យញ្ជនៈ និងស្រៈអ្វីខ្លះ ? គ្រូប្រើអក្សរចល័តបំបែកពាក្យ ឱ្យសិស្សមើល ។ ***ឧទាហរណ៍*** កា = ក ា , កី = ក ី , កួរ = ក ួ រ
- នាំសិស្សផ្សំព្យញ្ជនៈនឹងស្រៈ ឱ្យសិស្សថាតាម ។ ***ឧទាហរណ៍*** ក ា ⟶ កា , ក ី ⟶ កី

  ***ចំណាំ ៖*** ឯការបង្រៀនពាក្យដទៃ ធ្វើដូចបង្រៀនពាក្យ "កា" ដែរ ។
- ឱ្យសិស្សអានពាក្យនីមួយៗឡើងវិញ ដោយប្រកប ។ ***ឧទាហរណ៍*** កា = ក ា , កី = ក ី ...
- បង្រៀនពាក្យពីរព្យាង្គ "កកោះ" ដោយបង្ហាញសម្ភារៈ រួចបង្ហាញពាក្យ ។ បង្ហាញការបំបែកពាក្យជាព្យាង្គ កកោះ = ក កោះ និងផ្សំព្យាង្គ ។ ***ឧទាហរណ៍*** ក កោះ ⟶ កកោះ ។
- គ្រូអានពាក្យ កកោះ ។ ក ក េាះ កោះ កកោះ សិស្សអានពាក្យជាមួយគ្រូ រួចឱ្យសិស្សអាន ។
- គ្រូចង្អុលព្យាង្គ ពាក្យឆ្លាស់គ្នាឱ្យសិស្សអានជាបុគ្គល ឬគ្រូអានហៅសិស្សចង្អុល ។
- ឱ្យសិស្សរៀបអក្សរចល័តជាពាក្យ តាមការកំណត់របស់គ្រូ តាមក្រុមតូចៗ ។
- ឱ្យសិស្សអានព្យាង្គ ពាក្យ ល្បះនៅក្នុងសៀវភៅជាបុគ្គល ជាដៃគូឬក្រុម ដោយប្តូរវេនគ្នាចង្អុល ។

គ. ការបង្រៀនល្បះ

- គ្រូបង្ហាញផ្ទាំងរូបភាព បំផុសសំណួរ រឿងនិទាន កាយវិការ ដើម្បីបង្កើតល្បះដែលត្រូវបង្រៀន ។
- គ្រូចម្លងល្បះ ដាក់លើក្ដារខៀន ។ គ្រូអាចបំបែកល្បះជាផ្នែកតូចៗ(ពាក្យ) ដើម្បីឱ្យសិស្សងាយអាន ។ ***ឧទាហរណ៍*** កុំ កេះ កៃ ។
- គ្រូសួរសិស្ស តើល្បះនេះមានប៉ុន្មានពាក្យ ? (៣ពាក្យ) តើពាក្យ "កុំ" មានអក្សរអ្វីខ្លះ ? ...
- ឱ្យសិស្សអានពាក្យនីមួយៗ ដោយប្រកបដូចខាងក្រោម ៖
  ក អុំ កុំ , ក អេះ កេះ , ក អៃ កៃ , កុំ កេះ កៃ ។
- ឱ្យសិស្សផ្សំប័ណ្ណពាក្យជាល្បះ តាមក្រុមតូចៗ រួចអានល្បះនោះ ។

ឃ. ការបង្រៀនសរសេរព្យញ្ជនៈ ព្យាង្គ និងពាក្យ

- គ្រូសរសេរព្យញ្ជនៈ ក ឱ្យធំៗនៅលើក្ដារខៀន ដោយគូសសញ្ញាព្រួញអមផង ។
- គ្រូសរសេរព្យញ្ជនៈ ក ដោយគូសគំនូសម្ដងៗ តាមលំដាប់សញ្ញាព្រួញ ឱ្យសិស្សសង្កេត ព្រមទាំងនិយាយផង ។ ខ្ញុំគូសពីក្រោមឡើងលើ គូសពីឆ្វេងទៅស្ដាំ រួចគូសពីលើចុះក្រោម បន្ទាប់មក ដាក់សក់ ។
- គ្រូឱ្យសិស្សសរសេរ ក លើខ្យល់តាមគ្រូ ព្រមទាំងនិយាយ ។ គ្រូពិនិត្យ និងកែតម្រូវ ។
- គ្រូឱ្យសិស្សសរសេរ ក លើក្ដារឆ្នួន គ្រូពិនិត្យ និងកែលម្អ ។
  *ចំណាំ* ៖ គ្រូគប្បីដើរពិនិត្យពេលសិស្សសរសេរ ដើម្បីចៀសវាងការសរសេរបញ្ច្រាសទិស ។
- គ្រូហៅសិស្ស ៤-៥នាក់ សរសេរលើក្ដារខៀន ។
- គ្រូហៅព្យាង្គ ពាក្យខ្លះ ឱ្យសិស្សសរសេរ ។ ដំបូង គ្រូឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ ដោយសួរ ៖ "តើពាក្យ កី សរសេរដូចម្ដេច ? " ។ គ្រូឱ្យសិស្សថា កី សរសេរ ក ស្រៈ ី ខ្ញុំអានថា កី ។ កក្កូរ សរសេរ ក ក ស្រៈ ូ និង រ ខ្ញុំអានថា កក្កូរ សរសេរពាក្យនេះ លើក្ដារឆ្នួននិងក្ដារខៀន ។

## ៦.៥ លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈពួក អ៊ ផ្សំនឹងស្រៈ

លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈពួក [អ៊]ផ្សំនឹងស្រៈ គប្បីធ្វើតាមលំនាំបង្រៀនព្យញ្ជនៈពួក [អ]ផ្សំនឹងស្រៈដែរ គ្រាន់តែការអានមានសូរសំឡេងខុសគ្នាដូចខាងក្រោម ៖

ដំបូង គ្រូប្រាប់សិស្សថា ស្រះ ា ិ ី .... ោះ។ កាលណាប្រើជាមួយព្យញ្ជនៈពួក [អ៊] ដូចជា គ ឃ ង ... ត្រូវដូរសំឡេងទៅជា អ៊ា អ៊ិ អ៊ី អ៊ឹ អ៊ឺ អ៊ុ អ៊ូ អ៊ួ អ៊ើ អ៊ឿ អ៊ៀ អ៊េ អ៊ែ អ៊ៃ អ៊ោ អ៊ៅ អ៊ុំ អ៊ំ អ៊ាំ អ៊ះ អ៊ុះ អ៊េះ អ៊ោះ។ គ្រូគប្បីនាំសិស្សអាន អ៊ អ៊ា .....អ៊ោះ សិន។

គ អ៊ា គា គ អ៊ិ គិ គ អ៊ី គី គ អ៊ឹ គឹ គ អ៊ឺ គឺ គ អ៊ុ គុ

គ អ៊ូ គូ គ អ៊ួ គួ គ អ៊ើ គើ គ អ៊ឿ គឿ គ អ៊ៀ គៀ គ អ៊េ គេ

គ អ៊ែ គែ គ អ៊ៃ គៃ គ អ៊ោ គោ គ អ៊ៅ គៅ គ អ៊ុំ គុំ(គុម) គ អ៊ំ គំ

គ អ៊ាំ គាំ(គ័ម) គ អ៊ះ គះ គ អ៊ុះ គុះ គ អ៊េះ គេះ គ អ៊ោះ គោះ។

គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ។

## ៦.៦ លំនាំបង្រៀនអក្សរមានសញ្ញាមូសិកទន្ត ឬ ធ្មេញកណ្ដុរ( ៉ ) ឬសញ្ញា(អ៉ ) ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

- គ្រូយកផ្ទាំងព្យញ្ជនៈ ដាក់ផ្គូគ្នា។
- គ្រូចង្អុលអក្សរ ង ញ ប ម យ រ វ មួយតួម្ដងៗ រួចសួរសិស្សថា តើនេះជាអក្សរអ្វី ?

| | |
|---|---|
| ង | ង៉ |
| ញ | ញ៉ |
| ប | ប៉ |
| ម | ម៉ |
| យ | យ៉ |
| រ | រ៉ |
| វ | វ៉ |

- គ្រូចង្អុលអក្សរមួយម្ដងៗ និងបញ្ចេញសំឡេងឱ្យសិស្សស្ដាប់ និងថាតាម។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអានខ្លួនឯងជាក្រុមតូចៗ។ *ឧទាហរណ៍* ង ង៉។

- គ្រូសួរថា គូទី១ ក្នុងតារាងខាងលើ មានសំឡេងខុសគ្នាដូចម្ដេច ? តើវាខុសគ្នា ដោយសារអ្វី ? ដោយសារមានសញ្ញា ( ៉ ) គ្រូប្រាប់សិស្សថា សញ្ញា ( ៉ ) គេហៅថាសញ្ញា (អ) ឬធ្មេញកណ្ដុរ ឬមូសិកទន្ត។ កាលណាវាដាក់លើ ង ទៅជា ង៉ , ញ ទៅជា ញ៉ (មានសំឡេង អ) កាលណាវានៅជាមួយស្រៈ ិ ី ឹ ឺ ើ ៊ ាំ វាដូររាងជាបុកជើង ុ វិញ។

  ***ឧទាហរណ៍ ៖*** ញ៉ អាំ ញ៉ុាំ , ចា ប៉ ី ចាប៊ី។
- គ្រូនាំសិស្សអាន ង សម្លាប់ពីរ ង៉ , ញ សម្លាប់ពីរ ញ៉ ...ឱ្យសិស្សថាតាមម្នាក់ម្ដងៗ រួចជាក្រុម ទូទាំងថ្នាក់។
- គ្រូនាំសិស្សអានព្យាង្គ ង៉ា ង៊ិ ង៊ី ង៊ឹ ង៊ឺ ..................... ង៉ោះ ដោយបញ្ចេញសំឡេង ង៉ អា ង៉ា ង៉ អិ ង៊ិ ...........ង៉ អោះ ង៉ោះ។ រួច ង៉ា ង៊ិ ង៊ី ..........ង៉ោះ។
- គ្រូបង្រៀនពាក្យ ដោយនាំសិស្សប្រកបដូចពេលរៀនពាក្យមុនៗដែរ។

## ៦.៧ លំនាំបង្រៀនសញ្ញាត្រីស័ព្ទ ឬ សញ្ញាសក់ក ( ៊ ) ឬ សញ្ញា (អី)

សូមអ្នកគ្រូ លោកគ្រូបង្រៀនតាមលំនាំបង្រៀនមូសិកទន្ត ឬធ្មេញកណ្ដុរ។

## ៦.៨ លំនាំបង្រៀនព្យញ្ជនៈប្រកបនឹង □ក □ក់

### ក. ពាក្យពួក ( អ )

- គ្រូបង្ហាញអក្សរចល័ត ក រួចសួរថា តើនេះជាអក្សរអ្វី ? គ្រូយកអក្សរ ក មួយទៀតមកបង្ហាញ រួចសួរដូចមុន។
- គ្រូដាក់ផ្ទឹមគ្នា ក ក រួចអាន ក និង ក កក ឱ្យសិស្សថាតាមម្នាក់ម្ដងៗ ជាក្រុម និងទាំងអស់គ្នា។ គ្រូសរសេរពាក្យ កក លើក្ដារខៀន។ គ្រូបង្ហាញអក្សរ ខ រួចសួរដូចមុន។ គ្រូយកព្យញ្ជនៈ ក មកដាក់ជាប់នឹងព្យញ្ជនៈ ខ រួចឱ្យសិស្សអានថា ខ និង ក ខក រួចគ្រូសរសេរពាក្យ ខក នៅលើក្ដារខៀន។ បន្ទាប់មក ធ្វើដូចគ្នាចំពោះពាក្យ បក សក។
- គ្រូយកអក្សរ ក មកដាក់ជាមួយ ក ឱ្យសិស្សអានម្ដងទៀត រួចគ្រូដាក់សញ្ញាបន្តក់ពីលើ ក(តួប្រកប) ហើយនាំសិស្សអាន ក និង ក កក បន្តក់មួយ កក់។ ខ និង ក ខក បន្តក់មួយ ខក់។ ប្រាប់សិស្សថាសញ្ញានេះ ( ់ ) គេហៅថា បន្តក់។

- គ្រូបង្ហាញអក្សរ ក ា ក រួចប្រកប ក ា កា និង ក កាក , រួច ខ ា ខា និង ក ខាក ។
- គ្រូដូរពី ក ខាងចុងទៅជា ក់ ហើយនាំសិស្សអាន ៖ ក ា កា និង ក កាក បន្តក់មួយ កាក់ ។ ខ ា ខា និង ក ខាក បន្តក់មួយ ខាក់ ... ។
- គ្រូអានពាក្យឱ្យសិស្សស្ដាប់ និងថាតាមទាំងអស់គ្នា ៖

  *ឧទាហរណ៍ :*

  - ក និង ក កក , ក និង ក កក បន្តក់មួយ កក់
  - ក ា កា និង ក កាក , ក ា កា និង ក កាក បន្តក់មួយ កាក់
  - ផ ី ផី និង ក ផីក ...
  - រួចឱ្យសិស្សអាន កក កក់ ខក ខក់ កាក កាក់ ផីក ... ។
- ហៅសិស្សអានជាក្រុមតូចៗ រួចអានម្នាក់ម្ដងៗ ឱ្យបានច្រើនសា ដើម្បីឱ្យសិស្សចេះស្ទាត់ ។ (ចំពោះពាក្យមានន័យ គ្រូប្រើសម្ភារៈ រូបភាព ឬកាយវិការ ...ដើម្បីបំផុសឱ្យបានពាក្យនោះ និងឱ្យសិស្សយល់ន័យពាក្យ) ។
- គ្រូនាំសិស្សអានពាក្យទាំងនោះ តាមរបៀបអានខាងលើ ។ បន្ទាប់មក គ្រូនាំសិស្សអានល្បះដូចការអានល្បះក្នុងមេរៀនមុនៗដែរ ។
- ឱ្យសិស្សអានជាដៃគូ ដោយប្រើសៀវភៅរបស់ពួកគេ និងប្ដូរវេនគ្នាចង្អុល ។
- គ្រូចង្អុលពាក្យចោះៗ ឱ្យសិស្សអាន និងសរសេរលើក្ដារឆ្នួន ។
- គ្រូហៅសិស្សសរសេរពាក្យលើក្ដារខៀន ប្រណាំងគ្នាមួយគូៗ ។

## ខ. ពាក្យពួក ( អ៊ )

របៀបបង្រៀនពាក្យប្រកបពួក [អ៊] គប្បីបង្រៀនដូចពួក [អ] គ្រាន់តែគ្រូនាំសិស្សអានតាមសូរសំឡេងពួក [អ៊] ដូចជា ៖

- គ និង ក គក , ល និង ក លក ....
- គ និង ក គក បន្តក់មួយ គក់ , ល និង ក លក បន្តក់មួយ លក់
- គ អ៊ា គា និង ក គាក , គ អ៊ា គា និង ក គាក បន្តក់មួយ គាក់
- ល អ៊ា លា និង ក លាក , ល អ៊ា លា និង ក លាក បន្តក់មួយ លាក់ ... ។

## ៦.៩ លំនាំបង្រៀនស្រះពេញតួ

ការបង្រៀនស្រះពេញតួ គប្បីផ្ដើមចេញពីរូបភាព ឬសម្ភារៈផ្សេងៗ ដើម្បីបង្កើតពាក្យ ។ ***ឧទាហរណ៍*** បង្ហាញរូបភាពអគារ បង្ហាញពាក្យអគារ រួចបំបែកពាក្យជាពីរព្យាង្គ ។ ***ឧទាហរណ៍*** អគារ = អ គារ នាំសិស្សអានថា [អះគា] អគារ ។ បង្ហាញស្រះពេញតួចល័ត អ នាំសិស្សអាន អះ ។ គ្រូបង្រៀនពាក្យផ្សេងទៀត ដោយធ្វើដូចស្រះពេញតួ អ ដែរ ។ គ្រូអានស្រះពេញតួ រួចអានពាក្យឱ្យសិស្សស្ដាប់ ។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអាន ។ គ្រូហៅពាក្យឱ្យសិស្សសរសេរ ជាបន្តបន្ទាប់គ្នា ។

## ៦.១០ លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈផ្ញើជើង (ពួក អ និង អ៊ )

- គ្រូបង្ហាញអក្សរ ក ចល័ត រួចសួរ តើនេះជាអក្សរអ្វី ? គ្រូបង្ហាញជើង ្ល រួចសួរនេះជាអ្វី ? គ្រូយក ក ដាក់លើជើង ្ល រួចឱ្យសិស្សអានឱ្យស្ដាប់ ឬគ្រូអាន ។ គ្រូឱ្យសិស្សថាតាមទាំងអស់គ្នា ។ សិស្សថាជាក្រុមតូចៗ ។
- គ្រូយកស្រះ ា ិ ី ឹ ឺ មកផ្សំជាមួយ ក្ល មួយម្ដងៗ ហើយអានឱ្យសិស្សស្ដាប់ ឱ្យសិស្សថាជាក្រុម ឬជាបុគ្គល ។

  *ចំណាំ ៖* ចំពោះព្យញ្ជនៈផ្សំនឹងជើងផ្សេងទៀត គ្រូគប្បីធ្វើដូច ក ផ្សំនឹងជើង ្ល ដែរ ។
- គ្រូលើករូបភាព ឬរកឧទាហរណ៍បង្ហាញសិស្ស ដើម្បីបង្រៀនពាក្យ ក្បាល ...ឱ្យសិស្សប្រាប់ឈ្មោះរូបភាព ។ គ្រូបង្ហាញប័ណ្ណពាក្យ និងអានពាក្យឱ្យសិស្សថាតាម ។
- គ្រូនាំសិស្សវិភាគពាក្យដោយសួរសិស្សថា តើពាក្យ ក្បាល មានអក្សរអ្វីខ្លះ ? គ្រូសរសេរពាក្យនៅលើក្ដារខៀន ។ ***ឧទាហរណ៍*** ក្បាល = ក្ប ា ល (ក្បាល មាន ក្ប ស្រះ ា និង ល)
- គ្រូនាំសិស្សផ្សំពាក្យ ៖ ក្ប ា ល ⟶ ក្បាល ។ នាំសិស្សអាន ក្ប ា និង ល ក្បាល ។
- គ្រូសួរសិស្ស តើ ក្ប មានអក្សរអ្វីខ្លះ ? (ក្ប មាន ក ជើង ្ប) ប្រាប់សិស្សថាជើង ប ( ្ប) ក៏មានសូរសំឡេងដូចព្យញ្ជនៈ ប ដែរ ។ ប្រាប់សិស្សថា ការអានព្យញ្ជនៈផ្ញើជើង គេត្រូវអានព្យញ្ជនៈខាងលើមុន ក ហើយផ្សំសូររបស់ជើងព្យញ្ជនៈខាងក្រោម ្ប ទៅជា ក្ប ។
- គ្រូអានព្យាង្គឱ្យសិស្សស្ដាប់ ក ជើង ្ប ក្ប , ក ជើង ្ប ក្ប ក្ប ា ក្បា , ក ជើង ្ប ក្ប ក្បិ ... រួចឱ្យសិស្សអានជាក្រុម ជាបុគ្គល ។

- គ្រូនិងសិស្សអានពាក្យជាមួយគ្នា ។ *ឧទាហរណ៍* ក ជើង ្ប ក្ប ក្ប អា ក្បា ក្បា និង ល ក្បាល ។ *ចំណាំ ៖* ចំពោះពាក្យផ្សេងទៀត គ្រូបង្រៀនដូចពាក្យ ក្បាល ដែរ ។
- គ្រូហៅពាក្យឱ្យសិស្សចង្អុល និងចង្អុលពាក្យឱ្យសិស្សអាន ។
- ហៅសិស្សពូកែឡើងអានព្យាង្គ និងពាក្យនៅក្ដារខៀន រួចឱ្យសិស្សអាននៅក្នុងសៀវភៅតាមក្រុមតូចៗ ។
- គ្រូហៅពាក្យឱ្យសិស្សសរសេរ នៅលើក្ដារឆ្នួន ។ គ្រូហៅសិស្សឱ្យឡើងសរសេរ លើក្ដារខៀន ។

## ៦.១១ លំនាំបង្រៀនអាន និងសរសេរពាក្យព្យាង្គតម្រួត

- គ្រូចម្លងចំណងជើងមេរៀន (ង្ក ង្ខ ...) ដាក់លើក្ដារខៀន ។
- គ្រូបង្ហាញសម្ភារៈជាក់ស្ដែង ឬរូបភាពដើម្បីបំផុសរកពាក្យ ។
- គ្រូសរសេរពាក្យនោះនៅក្ដារខៀន ដោយប្រើដីសពណ៌ ។ គ្រូអានពាក្យនោះ ឱ្យសិស្សថាតាមក្រុមតូចៗ ។ សួរសិស្សថា តើពាក្យ .....មានអក្សរអ្វីខ្លះ ?
- គ្រូសរសេរវិធីបំបែកពាក្យនៅក្ដារខៀន ឬលើផ្ទាំងក្រដាសតាមលំនាំខាងក្រោម ជាអក្សរធំៗ ។ គ្រូអាចប្រើពណ៌ក្រហម សម្រាប់បន្តក់ និងជើងព្យញ្ជនៈ ឬប្រើប័ណ្ណអក្សរចល័ត ។ *ឧទាហរណ៍* អង្ករ = អង់ ករ ប្រាប់សិស្សថា អង្ករ ជាពាក្យ ២ព្យាង្គ ដែលសរសេរត្រួតគ្នា ឬហៅថាព្យាង្គតម្រួត ។
  - ព្យាង្គទី ១ អង់
  - ព្យាង្គទី ២ ករ
  - អ និង ង ត្រូវអានថា អង់ ជើង ្ក ត្រូវអានដូច ក ដែរ ជើង ្ក និង រ ត្រូវអានដូច ក និង រ គឺ ក ។ ដូច្នេះ អង្ករ ត្រូវអានថា អ និង ង អង់ ក និង រ ក អង្ករ ។
- គ្រូនាំសិស្សអានពាក្យព្យាង្គតម្រួត ឬធ្វើជើងដូចខាងក្រោម ៖
  - ង្ក ង្ខ ង្គ អានថា ង ជើង ក , ង ជើង ខ , ង ជើង គ ...
  - អ និង ង អង់ ក និង រ ក អង្ករ
  - កង្កែប = ក និង ង កង់ ក អែ កែ និង ប កែប កង្កែប
- ហៅសិស្សឡើងអានម្ដងម្នាក់ ឬអានជាក្រុមតូចៗ ។

- ហៅពាក្យឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ និងសរសេរលើក្ដារខៀន ។
- ចំពោះ ៖ ង្ក្រ ញ្ច្រ ន្ត្រ ....... ត្រូវអានដូចខាងក្រោម ៖
  - ង ជើង ក ជើង រ , ញ ជើង ច ជើង រ , ន ជើង ត ជើង រ
  - អង្ក្រង អានថា អ និង ង អង់ ក ជើង ្រ ក្រ ក្រ និង ង ក្រង = អង្ក្រង ។
  - កន្ត្រៃ អានថា ក និង ន កន់ ត ជើង ្រ ត្រ ត្រ អៃ ត្រៃ = កន្ត្រៃ ។

  *ចំណាំ ៖*

  ១. គ្រប់មេរៀន បើមានពាក្យ ឬឃ្លាច្រើន គ្រូមិនត្រូវបង្រៀនទាំងអស់នោះទេ គឺដកយកតែពាក្យ ឬឃ្លា ដែលសមស្របនឹងពេលវេលាមកបង្រៀន ឯពាក្យ ឬឃ្លានៅសល់ ត្រូវដាក់ជាកិច្ចការផ្ទះ ឬអំណានបន្ថែម ។

  ២. គ្រប់មេរៀន មិនត្រូវបង្រៀនអាន និងសរសេរនៅថ្ងៃផ្សេងៗគ្នាទេ គឺត្រូវបង្រៀននៅថ្ងៃជាមួយគ្នា ។ គ្រូអាចបង្រៀនអាន១ម៉ោង រួចបង្រៀនសរសេរ ១ម៉ោង ជាប់គ្នា ឬបង្រៀនពាក្យនីមួយៗអាន និងសរសេរជាមួយគ្នា ។

## ៦.១២ លំនាំបង្រៀនអំណានអត្ថបទ

### ក. លំណែនាំ

- ដើម្បីអានអត្ថបទបានល្អ មិនទាក់ មិនរដាក់រដុប និងយល់ន័យនៃអត្ថបទសិស្សត្រូវ ៖
  - ទី១ ៖ ស្គាល់តួអក្សរ ឱ្យបានច្បាស់លាស់
  - ទី២ ៖ ផ្អែកលើពាក្យ ឃ្លា និងល្បះខាងដើម ដើម្បីស្មានពាក្យដែលនៅបន្តបន្ទាប់
  - ទី៣ ៖ ស្វែងយល់ន័យ នៃល្បះនីមួយៗ
  - ទី៤ ៖ ស្គាល់សញ្ញាសម្គាល់ សញ្ញាវណ្ណយុត្ត( ។, ?... )ក្នុងអត្ថបទ ទើបអាចលើកដាក់សំឡេងបានសមស្រប ទៅតាមន័យរបស់អត្ថបទ ។
- គ្រូមិនត្រូវទម្លាប់សិស្ស ឬមិនត្រូវឱ្យសិស្សអានបង្ហួសនោះទេ ។

### ខ. លំនាំបង្រៀន

- គ្រូចម្លងអត្ថបទដាក់លើក្ដារខៀន ឬប្រើអត្ថបទក្នុងសៀវភៅសិស្ស
- គ្រូឱ្យសិស្សអានអត្ថបទ ដោយស្ងៀមស្ងាត់

- គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក ពាក្យមិនធ្លាប់ស្គាល់ និងពាក្យមិនទាន់យល់ន័យ រួចស្រង់ពាក្យពិបាកទាំងនោះដាក់លើក្ដារខៀន
- គ្រូអានពាក្យពិបាក ឱ្យសិស្សថាតាម និងធ្វើអក្ខរាវិរុទ្ធ
- គ្រូពន្យល់ពាក្យពិបាក ដោយប្រើរូបភាពជាជំនួយសម្រាប់ពាក្យរូបី ធ្វើកាយវិការ ឬលើកឧទាហរណ៍បញ្ជាក់ ។ល ។ ដើម្បីជួយឱ្យសិស្សយល់ន័យនៃពាក្យទាំងនោះ កាន់តែច្បាស់ ។
- គ្រូអានជាគំរូ ។ គ្រូនិងសិស្សអានជាមួយគ្នាមួយល្បះម្ដងៗ រហូតដល់ចប់ ដោយមានការអានតាមលំនាំផ្អាក និងដាក់សំឡេងនៅពេលបញ្ចប់ល្បះនីមួយៗ និងនៅត្រង់ដកឃ្លា ដោយប្រាប់សិស្សថា កាលណាឃើញដកឃ្លា គេត្រូវផ្អាកបន្តិច ទើបបន្តអានតទៅទៀត ។ កាលណាឃើញសញ្ញាខណ្ឌ " ។" ត្រូវដាក់សំឡេង ពីព្រោះវាបញ្ចប់ល្បះនីមួយៗ ។ កាលណាឃើញសញ្ញាសួរ " ?" ត្រូវលើកសំឡេងជាសំណួរ... ។
- គ្រូឱ្យសិស្សហាត់អានជាក្រុម តាំងពីដើមរហូតដល់ចប់ ។ គ្រូតាមដានកែលម្អ ។

## ៦.១៣ លំនាំបង្រៀនចម្រៀង (បទសារិកាកែវអើយ)

- គ្រូរំឭកសិស្សពីអ្វី ដែលហៅថាចម្រៀង រួចសួរសិស្ស ៖
  - តើប្អូនៗ ដែលឮគេច្រៀងចម្រៀង ឬទេ ?
  - តើប្អូនៗ ធ្លាប់ច្រៀងខ្លួនឯង ឬទេ ?
  - តើមានប្អូនណាខ្លះ ចេះច្រៀង ?
- គ្រូប្រាប់សិស្សថា យើងនឹងរៀនច្រៀងបទសារិកាកែវអើយឥឡូវនេះ
- គ្រូសរសេរអត្ថបទចម្រៀងខាងក្រោមដាក់លើក្ដារខៀន ៖

បទសារិកាកែវអើយ

សារិកាកែវអើយ
ស៊ីផ្លែដំបង
ស្លាបវាចាក់ក្បាច់
ប្រចឹកគ្នាលេង

ស៊ីអីកងៗ
ប្រចឹកគ្នាលេង ។
មាត់វាធ្វើភ្លេង
លើមែកព្រីក្សា ។

*(ដកស្រង់ចេញពីសៀវភៅកម្រងសិល្បៈសិក្សាដោយ នួន កន)*

- គ្រូអានវគ្គចម្រៀងមួយវគ្គម្តងៗ ច្បាស់ៗ ឱ្យសិស្សស្តាប់ ។ បន្ទាប់មក គ្រូចាប់ផ្តើមច្រៀងដោយធ្វើបទឱ្យសិស្សស្តាប់ រួចឱ្យសិស្សទាំងអស់គ្នាច្រៀងតាមមួយឃ្លាម្តងៗ ។
- គ្រូឱ្យសិស្សឡើងច្រៀងចម្រៀងជាក្រុម (មួយក្រុមមានគ្នា៤ ឬ៥នាក់) រហូតចប់គ្រប់គ្នា ។
- គ្រូគួរពន្យល់អត្ថន័យរបស់ចម្រៀង ឱ្យសិស្សទាំងអស់បានយល់ន័យចម្រៀងនេះផង ។

*បញ្ជាក់* ៖ ចម្រៀងអាចប្រើប្រាស់បាននៅគ្រប់ពេល ដែលសិស្សលែងចាប់អារម្មណ៍នឹងការសិក្សា ។ គ្រូគប្បីនាំសិស្សច្រៀង ដើម្បីប្តូរបរិយាកាសរៀនសូត្រ និងធ្វើឱ្យសិស្សចង់រៀនតទៅទៀត ។

## ៦.១៤ លំនាំបង្រៀនមេសូត្រ

### ក. លំណែនាំ

ការបង្រៀនសូត្រមេសូត្រ គឺមានបំណងឱ្យសិស្សចេះសូត្រតាមបទនីមួយៗ បានច្បាស់លាស់ត្រឹមត្រូវ ប្រកបដោយទឹកចិត្តសប្បាយរីករាយ ហើយចេះចាំអត្ថន័យ នៃមេសូត្រនីមួយៗថែមទៀតផង ។ ខាងក្រោមនេះ ជាលំនាំបង្រៀនមេសូត្រមួយជាឧទាហរណ៍ ។

### ខ. លំនាំបង្រៀន

- គ្រូប្រើសំណួរបំផុសផ្សេងៗ ទាក់ទងនឹងការសូត្រកំណាព្យ(មេសូត្រ)ដូចជា ៖
  - តើកូនៗធ្លាប់ស្តាប់គេសូត្រកំណាព្យ ឬមេសូត្រ ឬទេ ?
  - តើនរណាជាអ្នកសូត្រមេសូត្រ ឱ្យកូនៗស្តាប់ ?
  - តើគេសូត្រពីអ្វី ?
  - តើកូនៗនៅចាំ ហើយសាកល្បងសូត្រប្រាប់គ្រូបន្តិចផងបានទេ ?
- គ្រូប្រាប់សិស្សថា ឥឡូវនេះគ្រូនឹងសូត្រឱ្យកូនស្តាប់ម្តង ។
- គ្រូសរសេរអត្ថបទមេសូត្រ ខាងក្រោមដាក់លើក្តារខៀន ៖

ម៉ែឪមានគុណ　　　គុណមានទម្ងន់　　　ធ្ងន់ដូចប្រឹថពី
គ្មានអ្វីនឹងសង　　　គុណលោកទាំងទ្វី　　　មាសប៉ុនគិរី
ថ្លៃពុំស្មើហោង ។

- គ្រូអានអត្ថបទមេសូត្រខាងលើមួយឃ្លាម្តងៗ ឱ្យច្បាស់ៗ ឱ្យសិស្សស្តាប់ ។ បន្ទាប់មក គ្រូឱ្យសិស្សថាតាមទាំងអស់គ្នា ។
- គ្រូសូត្រដោយធ្វើបទឱ្យបានត្រឹមត្រូវ ឱ្យសិស្សស្តាប់ឡើងវិញម្តងទៀត ។
- គ្រូឱ្យសិស្សទាំងអស់ សូត្រធ្វើបទតាមគ្រូទាំងអស់គ្នា ។
- គ្រូឱ្យសិស្ស ២-៣នាក់ ឬសិស្សតាមក្រុមសូត្រធ្វើបទតាមគ្រូ ។
- គ្រូប្រាប់អត្ថន័យនៃកំណាព្យ ឱ្យសិស្សយល់ ។

## ៦.១៥ លំនាំបង្រៀនអក្សរផ្ចង់

### ក. លំណែនាំ

នៅថ្នាក់ទី១ សូមលោកគ្រូ អ្នកគ្រូបង្រៀនអក្សរផ្ចង់ទម្រង់អក្សរជ្រៀង ។

### ខ. លំនាំបង្រៀន

- គ្រូគូសបន្ទាត់ផ្តេក នៅលើក្តារខៀនតាមទម្រង់ ១/២ដូចគំរូខាងក្រោម ៖



- គ្រូណែនាំសិស្ស អំពីរបៀបគូសបន្ទាត់តាមគំរូខាងលើ ។ នៅក្នុងសៀវភៅសិស្ស មានក្រឡាបន្ទាត់ស្រេច ហើយគ្រូគ្រាន់តែនាំសិស្សគូសបន្ទាត់ទ្រេត តាមក្រឡាបន្ទាត់ក្នុងសៀវភៅសិស្សតែប៉ុណ្ណោះ ។
- គ្រូសរសេរគំរូនៅលើក្តារខៀនយឺតៗ តាមចលនានីមួយៗ ឱ្យសិស្សសង្កេតតាម ។ ដំបូងគ្រូសរសេរអក្សរ "ក" ដោយកំណត់យកកម្ពស់ ៤/៤ ទទឹង ២/៣ បន្ទាប់មកសរសេរតួអក្សរ "ក" ដោយកំណត់យកកម្ពស់ ២/៤ ទទឹង ១/៣ ។

- គ្រូឱ្យសិស្សហាត់សរសេរអក្សរ នៅលើក្ដារឆ្នួនតាមគំរូនៅលើក្ដារខៀន ។
  - គ្រូត្រួតពិនិត្យ និងកែលម្អ ។
  - គ្រូឱ្យសិស្សហាត់សរសេរអក្សរផ្ទង់នៅក្នុងសៀវភៅរៀងៗខ្លួន និងប្រមូលមកដាក់ពិន្ទុ ។

## ៦.១៦ លំនាំបង្រៀនសរសេរតាមអានរៀបចំ

### ក. លំណែនាំ

នៅថ្នាក់ទី ១ គ្រូគប្បីបង្រៀនសរសេរតាមអានរៀបចំបែបទី ១ ដែលគេថា "សរសេរតាមអានចម្លង" ឬ "ចម្លងតាមអាន"។ ពាក្យ កន្សោមពាក្យ និងល្បះ ដែលគ្រូយកមកឱ្យសិស្សសរសេរ ត្រូវជ្រើសរើសយកពាក្យ កន្សោមពាក្យ និងល្បះ ដែលបានរៀនរួចមកហើយ ។ ឯចំនួនពាក្យ និងកន្សោមពាក្យត្រូវមានពី ៥ ទៅ ១០យ៉ាងច្រើន និងល្បះចំនួន១ល្បះ ។

### ខ. លំនាំបង្រៀន

- គ្រូចម្លងពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទដាក់លើក្ដារខៀន ឬសរសេរលើក្រដាសផ្ទាំងធំ ។
- គ្រូគូសបន្ទាត់ពីក្រោមពាក្យ ដែលបម្រុងយកមកសរសេរ ហើយអានពាក្យនេះម្ដងៗ ឱ្យច្បាស់ៗ ឱ្យសិស្សចង្អុលពាក្យ និងអានតាម ២-៣នាក់ ។
- គ្រូអានពាក្យទាំងនោះដោយចង្អុលផង រួចឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ និងឱ្យសរសេរនៅលើក្ដារឆ្នួនទាំងអស់គ្នា ។ គ្រូដើរពិនិត្យ និងឱ្យសិស្សដែលសរសេរខុសកែឱ្យបានត្រូវឡើងវិញ ។
- គ្រូបន្តទៅពាក្យទី ២ ទី ៣ រហូតដល់ចប់ ដោយធ្វើតាមលំនាំបង្រៀនពាក្យទី១ដែរ ។
- គ្រូលាក់ពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទ ដែលត្រូវសរសេរតាមអាន រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ ។
- គ្រូហៅ ឬអានពាក្យ កន្សោមពាក្យ និងល្បះឡើងវិញ ឱ្យសិស្សផ្ទៀង ។ ទុកពេលសមល្មមឱ្យសិស្សកែ និងបំពេញបន្ថែម ។
- គ្រូប្រមូលកិច្ចការសិស្ស កែដាក់ពិន្ទុ ។
- គ្រូឱ្យសិស្សកែកំហុសពាក្យផ្ទាល់ខ្លួន ដោយឱ្យសិស្សឆូតពីលើពាក្យខុស ហើយសរសេរពាក្យត្រូវពីលើពាក្យនោះ ។ បើសិស្សណាសរសេរខុសច្រើន គប្បីឱ្យសិស្សនោះ ចម្លងពាក្យទាំងនោះឡើងវិញ ។

## ៦.១៧ លំនាំបង្រៀនសរសេរតាមអានចម្លង

- គ្រូសរសេរពាក្យមួយចំនួន នៅលើក្ដារខៀន
- គ្រូអានពាក្យមួយម្ដងៗ ឱ្យច្បាស់ៗ ហើយឱ្យសិស្ស ២-៣នាក់ឡើងចង្អុលពាក្យនីមួយៗ អានតាម
- គ្រូចង្អុលពាក្យទី១ និងអានម្ដងទៀត
- គ្រូឱ្យសិស្សធ្វើអក្ខរាវិញ្ញាសពាក្យនោះ រួចឱ្យសិស្សសរសេរនៅលើក្ដារឆ្នួនទាំងអស់គ្នា
- គ្រូត្រួតពិនិត្យ និងឱ្យសិស្សដែលសរសេរខុស កែឱ្យត្រូវឡើងវិញ
- គ្រូចង្អុលពាក្យទី ២ ទី ៣...រហូតគ្រប់ពាក្យ ហើយធ្វើតាមលំនាំបង្រៀនពាក្យទី ១ដែរ
- គ្រូហៅពាក្យឆ្លាស់គ្នា ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ
- គ្រូហៅពាក្យឡើងវិញឱ្យសិស្សផ្ទៀង រួចទុកពេលឱ្យសិស្សកែ និងបំពេញបន្ថែម
- គ្រូប្រមូលសៀវភៅសិស្ស និងកែដាក់ពិន្ទុ
- គ្រូឱ្យសិស្សកែកំហុសដោយខ្លួនឯងផ្ទាល់ ដោយឱ្យសិស្សឆូតពីលើពាក្យខុស ហើយសរសេរពាក្យត្រូវពីខាងលើពាក្យនោះ
- បើសិស្សណាសរសេរខុសច្រើនលើសពី ៥ពាក្យ គប្បីឱ្យសិស្សនោះចម្លងពាក្យទាំងអស់ឡើងវិញ ។

## ៦.១៨ លំនាំបង្រៀនសរសេរតាមអានត្រួតពិនិត្យ

- ដំបូង គ្រូអានពាក្យ កន្សោមពាក្យ និងល្បះ ដែលតម្រូវឱ្យសិស្សសរសេរ ឱ្យសិស្សទាំងអស់ស្ដាប់ដោយអានឱ្យឮ និងច្បាស់ៗ
- គ្រូអាន(ហៅ)ពាក្យ កន្សោមពាក្យ ឬ ឃ្លាខ្លីៗ បីដងឱ្យសិស្សសរសេរតាមមួយម្ដងៗ រហូតដល់ចប់ ។ គ្រូអាចឱ្យសិស្ស ២នាក់ ជួយថាតាម បន្ទាប់ពីគ្រូអានចប់ ដោយឱ្យសិស្សម្នាក់ថាតាមមុននឹងខ្លួនសរសេរ ហើយម្នាក់ទៀតថាតាមក្រោយពីខ្លួនសរសេររួច ។
- ក្រោយសិស្សសរសេរតាមអានចប់ គ្រូត្រូវអានម្ដងទៀតឱ្យឮ និងច្បាស់ៗឡើងវិញ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់និងកែតម្រូវពាក្យ កន្សោមពាក្យ និងល្បះ ដែលគេសរសេររំលង ឬខុស
- គ្រូប្រមូលកិច្ចការសិស្ស មកកែដាក់ពិន្ទុ ។

  *ចំណាំ ៖* ចំពោះការសរសេរតាមអានត្រួតពិនិត្យ លោកគ្រូ អ្នកគ្រូអាចអនុវត្តទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

# មេរៀនទី ១ រៀនគូសបន្ទាត់ និងខ្សែកោង



មេរៀនទី
២

# ចម្រៀងស្រៈ

(លំនាំបទសត្វទីទុយ)




ស្រៈអ ស្រៈអា ស្រៈអិ ស្រៈអី

ពីរបូកនឹងបីឱណាយើងលៃបានប្រាំ

ស្រៈអុ ស្រៈអូ ស្រៈអួ គួរចាំ

ប្រាំបូកនឹងប្រាំឱណាយើងចាំគឺដប់ ។

មេរៀនទី
៣

# ស្រៈនិស្ស័យ



# ចម្រៀងអក្ខរក្រម ៤ វគ្គ

(លំនាំបទតាចាស់ចង់បានប្រពន្ធក្មេង)

ក ខ **យើងត្រូវខិតខំ** គ **គិតរៀបចំទៅសាលារៀន**

ឃ ឃា **ស្តាប់គ្រូបង្រៀន** ង ងា **កុំអៀន** ក ខ គ ឃ ង ។

(**បន្ទរ** ៖ ក ខ គ ឃ ង)

ច ចា **រាបសារមទម** ឆ ឆី **សមរម្យ** ជ **ជួបសំពះ**

ឈ **ឈប់ធ្វើអ្វីផ្តេសផ្តាស** **ញញឹមកុំខ្មាស** ច ឆ ជ ឈ ញ ។

(**បន្ទរ** ៖ ច ឆ ជ ឈ ញ)

ដ ឋ ឌ ឍ **និងណ** **ពុកម៉ែត្រេកអរឃើញកូនទៅរៀន**

ត តា **តាមដំបូន្មាន** **សង្វាតស្វាត្ររៀន** ត ថ ទ ធ ន ។

(**បន្ទរ** ៖ ត ថ ទ ធ ន)

ប ផ ព ភ **និងម** **ស្រឡាញ់រាប់រកមិត្តភក្តិគ្រប់គ្នា**

យ រ ល វ **សាមគ្គា** ស ហ ឡ អ **ជាសាមសិបបីតួ** ។

(**បន្ទរ** ៖ យ រ ល វ ស ហ ឡ អ)

បញ្ជាក់ ៖ កន្លែងបន្ទរត្រូវឱ្យសិស្សស្រែកព្ចៗ ហើយឱ្យច្បាស់ៗ ។

មេរៀនទី ៤

# ព្យញ្ជនៈ ៣៣ តួ

| | | | | |
|---|---|---|---|---|
| ក | ខ | គ | ឃ | ង |
| ច | ឆ | ជ | ឈ | ញ |
| ដ | ឋ | ឌ | ឍ | ណ |
| ត | ថ | ទ | ធ | ន |
| ប | ផ | ព | ភ | ម |
| យ | រ | ល | វ | ស |
| ហ | ឡ | អ | | |

## មេរៀនទី ៥

# ក ក

ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ កេ កែ

កៃ កោ កៅ កុំ កំ កាំ កះ កុះ កេះ កោះ

**កា កី កាំ កេះ កោះ កួ(រ)**

**កកោះ កក(រ) កកូ(រ) កកេ(រ) កុះក(រ)**

កកែកក(រ)

កុំកេះកៃ ។



កោ(រ)



កកេ(រ)

មេរៀនទី
៦

# ខ ខ

ខ ខា ខិ ខី ខឹ ខឺ ខុ ខូ ខួ ខើ ខឿ ខៀ ខេ ខែ

ខៃ ខោ ខៅ ខុំ ខំ ខាំ ខះ ខុះ ខេះ ខោះ

ខែ ខោ ខំ ខាំ ខួ(រ)

ខះក កែខៃ

កៅខះក ។



ខែ



ខោ

# មេរៀនទី ៧ ច




ច ចា ចិ ចី ចឹ ចឺ ចុ ចូ ចួ ចើ ចឿ ចៀ ចេ ចែ

ចៃ ចោ ចៅ ចុំ ចំ ចាំ ចះ ចុះ ចេះ ចោះ

## ចា(រ) ចៃ ចោ(រ) ចៅ ចាំ ចុះ ចេះ ចោះ

## ច(រ)ចា

## ចៃខាំចៅកែ ។



ចា(រ)



ចុះ

មេរៀនទី
៨

# ឆ ឆ

ឆ ឆា ឆិ ឆី ឆឹ ឆឺ ឆុ ឆូ ឆួ ឆើ ឆឿ ឆៀ ឆេ ឆែ
ឆៃ ឆោ ឆៅ ឆុំ ឆំ ឆាំ ឆះ ឆុះ ឆេះ ឆោះ

**ឆា ឆី ឆៅ ឆេះ**

**ឆាឆៅ ឆេះខោ**

**ខោចៅកែឆេះ ។**

**ចែឆាំចេះឆា ។**



ឆា



ឆេះ

# រៀនសាឡើងវិញ

## ក ខ ច ឆ



កា



កី



ខែ



ចុះ



ឆា



ឆេះ

កា កី ខែ ខ្ជូ(រ) ចៃ ចុះ ឆៅ ឆេះ

ខះក កកេ(រ) ច(រ)ចា

កុំឆាឆៅចៅកែ ។

ចៅឆាំខំខាំកកេរ ។

*លំហាត់*

ចូរសរសេរអក្សរផ្គង់អំពីព្យញ្ជនៈ "ក" ។

# មេរៀនទី ៩

# ដ

ដ ដា ដិ ដី ដឹ ដឺ ដុ ដូ ដួ ដើ ដឿ ដៀ ដេ ដែ

ដៃ ដោ ដៅ ដុំ ដំ ដាំ ដះ ដុះ ដេះ ដោះ

**ដី ដៃ ដុំ ដំ ដាំ ដុះ ដូ(រ) ដើ(រ) ដេ(រ)**

**កដៃ ដាំដុះ ដុំដី**

**ដោះដូ(រ) ដេ(រ)ខោ**

ដាដេ(រ)ខោ ។

ចៅកែចេះដាំដុះ ។



ដាំ



ដើ(រ)



ដេ(រ)

# មេរៀនទី ១០ ឋ




ឋ ឋា ឋិ ឋី ឋឹ ឋឺ ឋុ ឋូ ឋួ ឋើ ឋឿ ឋៀ ឋេ

ឋែ ឋៃ ឋោ ឋៅ ឋុំ ឋំ ឋាំ ឋះ ឋុះ ឋេះ ឋោះ

## ឋានីយ

## ចៅឋូដូ(រ)ឆោ ។



ឋានីយ

មេរៀនទី
១១

# ណ




ណ ណា ណិ ណី ណឹ ណឺ ណុ ណូ ណួ ណើ ណឿ ណៀ ណេ

ណែ ណៃ ណោ ណៅ ណុំ ណំ ណាំ ណះ ណុះ ណេះ ណោះ

**ចំណី ចំណាំ ចំណុះ**

**ចំណេះ ដំណើ(រ)**

កុំស៊ីចំណីឆៅ ។

ចៅណូចេះដាំដំណាំ ។



ចំណី

# រៀនសាឡើងវិញ
# ដ ឋ ណ

ចំណោះ ចំណាំ ដំណើ(រ) កដៃ ដុំដី ដំណាំ

ចំណីឆៅ

កុំដោះដូ(រ)ដី ។

ចៅឋេខំដាំដំណាំ ។

*លំហាត់*

១. ចូរគូសភ្ជាប់រូបឱ្យត្រូវនឹងពាក្យខាងក្រោម ៖







ដំ ដេ(រ) ខោ

២. ចូរសរសេរអក្សរផ្គុំអំពីព្យញ្ជនៈ "ដ" ។

# មេរៀនទី ១២ ត ថ

ត តា តិ តី តឹ តឺ តុ តូ តួ តើ តឿ តៀ តេ តែ
តៃ តោ តៅ តុំ តំ តាំ តះ តុះ តេះ តោះ

តា តោ តៅ ថៃ ថូ ថេ(រ)

តាខេ ដើ(រ)តួ តេះតះ

ថៅតូដើ(រ)តេះតះ ។

តាថេចាំថៅតូចុះដី ។



តៅ



តាខេ



ថូ



តោ

# មេរៀនទី ១៣ ប ប ផ ផ

ប បា បិ បី បឹ បឺ បុ បូ បួ បើ បឿ បៀ ផេ ផែ

ផៃ ផោ ផៅ ផុំ ផំ ផាំ ផះ ផុះ ផេះ ផោះ

**បា បឺ បៅ បេះ ផែ ផេះ**

**ដំបែ ដំបៅ បប(រ) កាផា**

**ចៅបូបៅដោះ ។**

**បូផាដាំបប(រ) ។**



កាផា



ផែ



ដាំបប(រ) ។



ចៅបូបៅដោះ ។

# រៀនសាឡើងវិញ

## ត ថ ប ផ

តា តៅ ថៃ ថេ(រ) ថោះ ផៃ ប៊ី

បៅ បេះ ផេះ

តេះតះ ថៅកែ ដំបែ បំបៅ កាផា

ថៅកែថៃថ្ងូ ។ កុំថាំតែថា ។

ថៅបួដើ(រ)តេះតះ ។

*លំហាត់*

១. ចូរបំពេញតួព្យញ្ជនៈជាមួយស្រៈឱ្យត្រូវនឹងរូបខាងក្រោម ៖



េ□ា



□ូ

២. ចូរសរសេរតាមអានចម្លងនូវពាក្យចំនួនប្រាំ ។

# មេរៀនទី ១៤ ស ហ

ស សា សិ សី សឹ សឺ សុ សូ សួ សើ សឿ សៀ ហេ ហែ ហៃ

ហោ ហៅ ហុំ ហំ ហាំ ហះ ហុះ ហេះ ហោះ

**សី សោ សេះ សួ(រ) ហូ(រ) ហើ(រ) ហោះ**

**សស(រ) ស(រ)សេ(រ) ហូ(រ)ហែ**

**សំណួ(រ) ស(រ)សើ(រ)**

ចៅហែខិស(រ)សេ(រ) ។

តាសំស(រ)សើ(រ)សុខា ។



សេះ



ហើ(រ)



សី



ហោះ

# មេរៀនទី ១៥ ឡ អ





ឡ ឡា ឡិ ឡី ឡឹ ឡឺ ឡុ ឡូ ឡួ ឡើ ឡឿ ឡៀ អេ អែ អៃ

អោ អៅ អុំ អំ អាំ អះ អុះ អេះ អោះ

ឡូ អុំ អូ(រ)

កីឡា សំឡី ឡេះឡោះ

កៅអី អំបោះ អាហា(រ)

ចៅអាំដើ(រ)ឡេះឡោះ ។

សុខាកា(រ)អំបោះ ។



ឡូ



អា(រ)



កីឡា



អំបោះ



កៅអី

# រៀនសាឡើងវិញ

## ក ខ ច ឆ ដ ប ណ ត ថ

## ប ផ ស ហ ឡ អ

តា ណា កី ឆី តុ ថូ បួ តើ បើ តឿ ខែ ផែ ដៃ

ខោ សោ ហៅ ប៉ៅ ខំ ដំ ដាំ ខាំ បះ សះ ចុះ

ឆេះ សេះ ដោះ បោះ ហោះ

បែ(រ) ដេ(រ) សូ(រ) សួ(រ) ហូ(រ) អូ(រ) ដើ(រ)

ហើ(រ) អំបោះ ដំបៅ ហូ(រ)ហែ ស(រ)សេ(រ)

សំណួ(រ) ឡេះឡោះ ចំហ អាហា(រ) កៅអី

ថៅកែអាំឡូឡា ។ ខោតាណៃឆេះ ។ សំដើ(រ)ចុះផែ ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖

   

.......... .......... .......... ..........

២. ចូរសរសេរអក្សរផ្សំអំពីព្យញ្ជនៈ "ហ" ។

មេរៀនទី ១៦

# គ គ

គ គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ គេ គែ
គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ

**គេ គែ គោ គុំ គោះ គ(រ) គូ(រ) គួ(រ)**

**គោបា សាគ(រ) សាគូ អគា(រ) គគី(រ)**

ថៅគាគូ(រ)គោ ។

តាគីបេះគ ។



គោបា



អគា(រ)

មេរៀនទី
១៧

# ឃ ឃ

ឃ ឃា ឃិ ឃី ឃឹ ឃឺ ឃុ ឃូ ឃួ ឃើ ឃឿ ឃៀ ឃេ ឃែ ឃៃ
ឃោ ឃៅ ឃុំ ឃំ ឃាំ ឃះ ឃុះ ឃេះ ឃោះ

ឃ្ងូ(រ)ៗ ឃោ(រ)ឃៅ គឃៀ(រ)

គេឃុំចោ(រ) ។

តាឃីដើ(រ)សំដៅសាលាឃុំគគី(រ) ។



ឃ្ងូ(រ)ៗ



សាលាឃុំ

មេរៀនទី
១៨

# ង




ង ងា ងិ ងី ងឹ ងឺ ងុ ងូ ងួ ងើ ងឿ ងៀ ងេ ងែ

ងៃ ងោ ងៅ ងុំ ងំ ងាំ ងះ ងុះ ងេះ ងោះ

**ងា(រ) ងឿ ងំ**

**កា(រ)ងា(រ) ងឹងើ ដំបៅងា**

ចៅងឹសះដំបៅងា ។

សុខាចេះង(រ) ។



ងឿ



សុខាចេះង(រ) ។

មេរៀនទី ១៩

# ជ



ជ ជា ជិ ជី ជឹ ជឺ ជុ ជូ ជួ ជើ ជឿ ជៀ ជេ ជែ

ជៃ ជោ ជៅ ជុំ ជំ ជាំ ជះ ជុះ ជេះ ជោះ

**ជី(រ) ជូ(រ) ជួ(រ) ជឿ ជេ(រ) ជាំ ជោ(រ)**

**ជីតា ជំងឺ បូជា**

កុំជឿគេ ។

តាតែដាំជី(រ)ជាជួ(រ) ។



ជី(រ)



ជំងឺ

# មេរៀនទី ២០ ឈ



ឈ ឈា ឈិ ឈី ឈឹ ឈឺ ឈុ ឈូ ឈួ ឈើ ឈឿ ឈៀ ឈេ

ឈែ ឈៃ ឈោ ឈៅ ឈុំ ឈំ ឈាំ ឈះ ឈុះ ឈេះ ឈោះ

**ឈ(រ) ឈឺ ឈើ**

**អា(រ)ឈើ ឈឺដៃ ឈូឆ(រ)**

បូណាឈ(រ) ។

គេដើ(រ)ឈូឆ(រ) ។ តាឈុំអា(រ)ឈើ ។



បូណាឈ(រ) ។



តាឈុំអា(រ)ឈើ ។

មេរៀនទី ២១

# ញ




ញ ញា ញិ ញី ញឹ ញឺ ញុ ញូ ញួ ញើ ញឿ ញៀ ញេ ញែ ញៃ

ញោ ញៅ ញុំ ញំ ញាំ ញះ ញុះ ញេះ ញោះ

## ញី ញាំ ញុះ ញោះ

## ញញួ(រ) គោញី

## កុំញុះគេ ។

## ចៅកែគូ(រ)គោញី ។



ញញួ(រ)



ចៅកែគូ(រ)គោញី ។

# រៀនសាឡើងវិញ

## គ ឃ ង ជ ឈ ញ

គេ ឃុំ ឈឺ ញាំ

គូ(រ) ងា(រ) ជេ(រ) ជោ(រ) ជួ(រ) ឈ(រ)

គគី(រ) គោញី យោ(រ)យៅ ងីងើ ញញូ(រ)

ដំបៅងា

សំចេះគូ(រ)គោញី ។

ចៅជាឈ(រ)ងីងើ ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖





. . . . . . . . . . . . . . . . . . . . . . . . . . . . . .

២. ចូរសរសេរអក្សរផ្គង់អំពីព្យញ្ជនៈ “ឈ” ។

# មេរៀនទី ២២

# ឌ ឌ

ឌ ឌា ឌិ ឌី ឌឹ ឌឺ ឌុ ឌូ ឌួ ឌើ ឌឿ ឌៀ ឌេ ឌែ

ឌៃ ឌោ ឌៅ ឌុំ ឌំ ឌាំ ឌះ ឌុះ ឌេះ ឌោះ

ឌី

ចៅឌឿចេះដើ(រ) ។

ឌីណាដាំដី(រ) ។

តាឌុំឈ(រ)ចាំចៅ ។



តាឌុំឈ(រ)ចាំចៅ ។



ចៅឌឿចេះដើ(រ) ។



ឌីណាដាំដី(រ) ។

# មេរៀនទី ២៣

# ឈ



ឈ ឈា ឈិ ឈី ឈឹ ឈឺ ឈុ ឈូ ឈួ ឈើ ឈឿ ឈៀ ឈេ ឈែ ឈៃ

ឈោ ឈៅ ឈុំ ឈំ ឈាំ ឈះ ឈុះ ឈេះ ឈោះ

**ឈាមរា**

ចៅឈឺចាំតាឌុំ ។



**ឈាមរា**

# មេរៀនទី ២៤ ទ  ធ 

ទ ទា ទិ ទី ទឹ ទឺ ទុ ទូ ទួ ទើ ទឿ ទៀ ធេ ធែ

ធៃ ធោ ធៅ ធុំ ធំ ធាំ ធះ ធុះ ធេះ ធោះ

**ទា ទី ទូ ធា(រ) ធុំ ទៅ ទុំ ធូ(រ) ទះ ទើ(រ)**

**ទទា ទីទៃ សាធុ ទូទៅ**

**ទទេ ទទូ(រ) ដទៃ សាទ(រ)**

ខោសុធាធូ(រ) ។

ទទាហើ(រ)ទៅទីទៃ ។



ខោសុធាធូរ ។



ទូ



ទុំ



ទទា

# រៀនសាឡើងវិញ

## ឌ ឈ ទ ធ

ឌី ឌឺ ឌុំ ទូ ទេ ទៅ ទុំ ធំ ទើ(រ) ទេ(រ) ទោ(រ)
